**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

# បទអន្តរាគមន៍៖

# ការរួមចំណែករបស់វិស័យអភិវឌ្ឍន៍ជនបទក្នុងវិស័យធនធានទឹក



ថ្ងៃពុធ ១៥រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០២៥

# មាតិកា

១. សេចក្តីផ្តើម

២. សកម្មភាព និងលទ្ធផលការងារសម្រេច បានទាក់ទងនឹងវិស័យធនធានទឹក ២០២៦

៣. ផែនការសម្រាប់ឆ្នាំ ២០២៦

៤. បញ្ហាប្រឈម និងសំណូមពរ

## ១ សេចក្ដីផ្ដើម

# ក្រសួងអភិវឌ្ឍន៍ជនបទ

↓

**កសាងសង្គមជនបទកម្ពុជាឱ្យមានវិបុលភាព ប្រកបដោយបរិយាបន្ន សមធម៌ និងចីរភាព**

# ១ សេចក្ដីផ្ដើម

**ក្រសួងអភិវឌ្ឍន៍ជនបទ** បានដាក់ចេញនូវកម្មវិធីជាអាទិភាពចំនួន៥៖



# ១ សេចក្តីផ្តើម

## ភារកិច្ចរបស់ក្រសួងអភិវឌ្ឍន៍ជនបទក្នុងការងារផ្គត់ផ្គង់ទឹកជនបទ

- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការវិនិយោគ និងផែនការសកម្មភាព លើវិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ រយៈពេលខ្លី មធ្យម និងវែង
- សហការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យផ្គត់ផ្គង់ទឹកស្អាតជនបទ
- គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដែលគ្មានលក្ខណៈអាជីវកម្ម និងមិនស្វែងយកប្រាក់ចំណេញនៅតំបន់ជនបទកម្រិតគ្រួសារ សហគមន៍ ភូមិ និងឃុំ
- សាងសង់ និងជួសជុលប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ រួមមាន៖ អណ្តូងស្នប់ ប្រព័ន្ធចែកចាយទឹកតាមបណ្តាយបំពង់ខ្នាតតូចសហគមន៍ ស្ថានីយ៍ផលិតទឹកផឹកសហគមន៍ ស្រះសហគមន៍ ប្រព័ន្ធត្រង់ទឹកភ្លៀង និងធុងចម្រោះ ។ល។
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា និងវិស័យឯកជន ដែលទាក់ទងនឹងកម្មវិធីផ្គត់ផ្គង់ទឹកស្អាតជនបទ។

# ១ សេចក្តីផ្តើម

## ភាពពាក់ព័ន្ធជាមួយក្រសួងធនធានទឹក និងឧតុនិយម

**កម្មវិធីទី២៖**

**ការកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ៖**

**ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ**

# ២ សកម្មភាព និងលទ្ធផលការងារសម្រេចបាន

## ២.១ ឯកសារគតិយុត្តិពាក់ព័ន្ធនឹងការងារផ្គត់ផ្គង់ទឹកជនបទ
























# ២ សកម្មភាព និងលទ្ធផលការងារសម្រេចបាន

## ២.១ ឯកសារគតិយុត្តិពាក់ព័ន្ធនឹងការងារផ្គត់ផ្គង់ទឹកជនបទ



# ២ សកម្មភាព និងលទ្ធផលការងារសម្រេចបាន

## ២.២ យន្តការ

- ក្រុមការងារត្រី វិស័យ-កសិកម្ម-ទឹក-ជនបទ
- ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងលើកម្ពស់អនាម័យជនបទ (TWG-RWSSH) --យន្តការអន្តរក្រសួង
- ក្រុមការងារបច្ចេកទេសថ្នាក់ខេត្តលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទ (PWG-RWSSH)--យន្តការថ្នាក់ខេត្ត
- សហប្រតិបត្តិការលើវិស័យធានធានទឹកតាមរយៈ គម្រោងសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា
- យន្តការសម្របសម្រួលអន្តររវាងក្រសួងទាំងពីរ--សម្របសម្រួល និងជដៃកពិភាក្សាលើបញ្ហាពាក់ពន្ធ ជាពិសេសហេដ្ឋារចនាសម្ព័ន្ធទឹកនៅជនបទ

# ២ សកម្មភាព និងលទ្ធផលការងារសម្រេចបាន

## ២.៣ សកម្មភាពដែលបានអនុវត្តន៍

- សម្របសម្រួល សហការ និងជជែកពិភាក្សាទៅលើបញ្ហាដែលកើតមានពាក់ព័ន្ធនឹងធនធានទឹក ជាពិសេសនៅថ្នាក់ក្រោមជាតិ
- ចូលរួមប្រជុំពិភាក្សាលើបញ្ហាផ្សេងៗ តាមរយៈ គម្រោងសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍នានា លើការងារគ្រប់គ្រង និងប្រើប្រាស់ធនធានទឹក
- បន្ស៊ីដែនសមត្ថកិច្ច និងសហការរវាងក្រសួងទាំងពីរលើការងារពាក់ព័ន្ធដូចជា ការងារធារាសាស្ត្រ សហគមន៍កសិករប្រើប្រាស់ទឹក និងការឆ្លើយនឹងទឹកជំនន់ តាមរយៈយន្តការត្រីវិស័យ កសិកម្ម-ទឹក-ជនបទ
- ជំរុញ និងបង្កើនសកម្មភាពក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ។

# ២ សកម្មភាព និងលទ្ធផលការងារសម្រេចបាន

២.៤ សមិទ្ធផលសំខាន់ៗ

- គិតត្រឹមឆ្នាំ ២០២៥ អាត្រាគ្របដណ្តប់ទឹកស្អាតជនបទដែលមានការកែលម្អ (IMPROVED WATER) សម្រេចបាន **៨៩ % (ការផ្គត់ផ្គង់ទឹកស្អាតដែលមានការកែលម្អ** សំដៅទៅទឹកបរិភោគដែលបានមកពីប្រភពទឹកដែលមានការកែលម្អ ប៉ុន្តែចំណាយពេលវេលាមិនលើសពី៣០នាទី ក្នុងការធ្វើដំណើរទៅយកទឹកមករួមទាំងការរងចាំ។
- គិតត្រឹមឆ្នាំ ២០២៥ អាត្រាគ្របដណ្តប់ទឹកស្អាតជនបទប្រកបដោយសុវត្ថិភាព (SAFELY MANAGED) សម្រេចបានប្រមាណ **២៥% (ការទទួលបានសេវាទឹកស្អាតប្រកបដោយសុវត្ថិភាព**សំដៅទៅលើទឹកបរិភោគដែលបានពីប្រភពទឹកដែលមានការកែលម្អស្ថិតក្នុងបរិវេណលំនៅដ្ឋានដែលអាចរកបានពេលដែលត្រូវការ និងមិនមានមេរោគ និងសារធាតុគីមីលើសលប់។

# ២ សកម្មភាព និងលទ្ធផលការងារសម្រេចបាន

## ២.៤ សមិទ្ធផលសំខាន់ៗ



# ៣ ផែនការសម្រាប់ឆ្នាំ ២០២៦

- បន្តជំរុញ និងពង្រឹងកិច្ចសហការដើម្បីសម្រេចគោលដៅលើអត្រាគ្របដណ្តប់ទឹកស្អាតឱ្យបាន ១០០ % នៅឆ្នាំ២០៣០ ស្របតាមកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា សម្រាប់ការកសាង និងការការពារមាតុភូមិឆ្នាំ ២០២៣-២០២៨ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា
- បន្តជំរុញអត្រាទទួលបានសេវាទឹកស្អាតគ្រប់គ្រងដោយសុវត្ថិភាពដល់ ៥០% និងអនាម័យគ្រប់គ្រងដោយសុវត្ថិភាពដល់ ៧០% នៅឆ្នាំ ២០៣៣
- បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រសួងធនធានទឹក និងឧតុនិយម នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (មន្ទីរ និងមន្ទីរ ) និងស្ថាប័នពាក់ព័ន្ធ
- បន្តពង្រឹងយន្តការក្រុមការងារត្រី-វិស័យ-កសិកម្ម-ទឹក-ជនបទ

# ៣ ផែនការសម្រាប់ឆ្នាំ ២០២៦

- បន្តសហការរៀបចំឯកសារគតិយុត្តិពាក់ព័ន្ធនានា ទាក់ទងនឹងការងារផ្គត់ផ្គង់ទឹកជនបទ និងធនធានទឹកមានជាអាទិ៍៖ អនុស្សារណៈយោគយល់លើការងារផ្គត់ផ្គង់ទឹក និងធនធានទឹក
- បញ្ចប់ការងាររៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្ដីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងបកប្រែជាខេមរៈភាសា
- បន្តផ្សព្វផ្សាយអំពីឯកសារ និងបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹក និងធនធានទឹក ជាពិសេសនៅថ្នាក់ក្រោមជាតិ។

# ៤ បញ្ហាប្រឈម និងសំណូមពរ

## ៤.១ បញ្ហាប្រឈម

- វិសមភាពនៃអត្រាទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ប្រឈម ក្រុមងាយរងគ្រោះនឹងការប្រែប្រួលអាកាសធាតុ
- ការគាំទ្រផ្នែកហិរញ្ញវត្ថុលើការងារផ្គត់ផ្គង់ទឹកស្អាតនៅជនបទមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង
- កង្វះខាតប្រព័ន្ធទិន្នន័យ និងពត៌មានទាក់ទងនឹងការផ្គត់ផ្គង់ទឹកជនបទ
- ភាពជាម្ចាស់ និងចំណេះដឹងរបស់សហគមន៍។

## ៤.២ សំណូមពរ

- យកចិត្តទុកដាក់តំបន់ប្រឈម ដាច់ស្រយ៉ាល ក្រុមងាយរងគ្រោះ និងការប្រែប្រួលអាកាសធាតុ
- ខិតខំកៀរគរធនធានបន្ថែម និងបង្កើនកិច្ចសហប្រតិបត្តិការតាមរយៈយន្តការផ្សេងៗ
- ពង្រឹងប្រព័ន្ធទិន្នន័យពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកជនបទ
- បន្តអបរំ និងបណ្តុះបណ្តាលសហគមន៍។

# សូមអរគុណ !